**សម្រាប់ផ្សព្វផ្សាយភ្លាម**

**ទំនាក់ទំនង:** *នៅភ្នំពេញ:* ប៊ូ សារឿន (៨៥៥) ០២៣-២១៧-៣០១
sbou@worldbank.org

# ធនាគារពិភពលោកនិងពហុស្ថាប័នផ្តល់ជំនួយ ជួយប្រទេសកម្ពុជាក្នុងការកែលម្អការសម្រួលពាណិជ្ជកម្ម

**ភ្នំពេញ ថ្ងៃខែ ១៤ ឆ្នាំ ២០០៩ -** រាជរដ្ឋាភិបាលកម្ពុជានឹងទទួលហិរញ្ញប្បទានជំនួយឥតសំណងក្នុងទឹកប្រាក់ចំនួន ១២,៦ លានដុល្លារអាមេរិក ពីស្ថាប័នផ្តល់ជំនួយចំនួនបីដើម្បីជួយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ថ្មីមួយ ដែលសំដៅកាត់បន្ថយភាពក្រីក្រដោយលុបបំបាត់ឧបសគ្គពាណិជ្ជកម្ម និងកែលម្អបទដ្ឋាននៃការនាំចេញកម្ពុជា។

កម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្មកម្ពុជា ឬ TDSP គឺសំដៅពង្រឹងប្រសិទ្ធិភាពរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងការអនុវត្តគោលនយោបាយពាណិជ្ជកម្មប្រកបដោយប្រសិទ្ធិភាព ក្នុងការបំពេញករណីកិច្ចរបស់ខ្លួនចំពោះអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងបទដ្ឋានសុវត្ថិភាពស្បៀងអាហារ និងក្នុងការកែលម្អលទ្ធភាពរបស់សហគ្រាសកម្ពុជាក្នុងការចូលក្នុងទីផ្សារអឺរ៉ុប នៅក្នុងចំណោមគោលដៅផ្សេងៗទៀត។

នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា លោកស្រី **អាណែត ឌិកសិន (Annette Dixon)** មានប្រសាសន៍ថា: *"នៅក្នុងបរិបទនៃវិបត្តិហិរញ្ញវត្ថុពិភពលោក និងការចុះខ្សោយនៃលំហូរពាណិជ្ជកម្ម កិច្ចប្រឹងប្រែងទាំងនេះមានលក្ខណៈកាន់តែ សំខាន់ឡើងថែមទៀត"* ។

*"នៅធនាគារពិភពលោក យើងជឿថាពាណិជ្ជកម្មបំពេញតួនាទីដ៏សំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ពាណិជ្ជកម្មបង្កើតសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ចខ្ពស់ និងការងារ។ ដោយជួយរាជរដ្ឋាភិបាលក្នុងការបង្កើនពាណិជ្ជកម្ម និងការងារនៅក្នុងវិស័យទាក់ទិននឹងពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលរួមចំណែកដល់កម្មវិធីនេះ និងអាចជួយប្រជាជនកម្ពុជាឱ្យមានជីវិតកាន់តែប្រសើរឡើង។"*

មូលនិធិសម្រាប់កម្មវិធីនេះបានមកពីមូលនិធិមរតកសម្រាប់អភិវឌ្ឍន៍ពាណិជ្ជកម្មកម្ពុជា (Trade Development Trust Fund) និងត្រូវបានឧបត្ថម្ភដោយ គណៈកម្មការអឺរ៉ុបជាមួយនឹងទឹកប្រាក់ ៧,១ លានយូរ៉ូ ទីភ្នាក់ងារជំនួយអន្តរជាតិដាណឺម៉ាក (DANIDA) មានទឹកប្រាក់ ៣៣ លាន DKK និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្ម

សហប្រជាជាតិ (UNIDO) ដែលទឹកប្រាក់ ០,២ លានយូរ៉ូ ហើយធនាគារពិភពលោកជាអ្នកគ្រប់គ្រង និងផ្តល់ឱវាទបច្ចេកទេស និងតាមដានក៏ដូចជាវាយតម្លៃលើផលប៉ះពាល់នៃកម្មវិធីនេះនេះ តាងនាមឱ្យស្ថាប័នផ្តល់ជំនួយទាំងអស់។

ពាណិជ្ជកម្មអន្តរជាតិ គោលនយោបាយពាណិជ្ជកម្មបើកទូលាយ និងការស្ថិតនៅក្នុងអនុតំបន់អាស៊ីអគ្នេយ៍ប្រកបដោយថាមភាពខ្លាំង សុទ្ធតែបានរួមចំណែកយ៉ាងច្រើនដល់កំណើនដ៏លឿននៃប្រទេសកម្ពុជាក្នុងទសវត្សរ៍កន្លងទៅនេះ។ ការនាំចេញសម្លៀកបំពាក់ និង វិស័យទេសចរណ៍ គឺជាវិស័យនាំមុខដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសនេះ។

ប្រទេសកម្ពុជា ដែលបានចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ ២០០៤ បាននិងកំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅក្នុងវិស័យកាត់ដេរពីប្រទេសមួយចំនួន។ម្យ៉ាងទៀត កង្វះខាតនៃពិពិធកម្មទាំងនៅក្នុងទំនិញនាំចេញ និង ទាំងនៅក្នុងទីផ្សារនាំចេញ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈងាយរងគ្រោះក្នុងកម្រិតមួយចំពោះការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ដែលដឹកនាំដោយសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ន។

ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងជាប្រចាំរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនាំចេញ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់បង្ហើយយុទ្ធសាស្ត្រសមាហរណវិភាគកម្មពាណិជ្ជកម្ម (DTIS) ក្នុងឆ្នាំ។ យុទ្ធសាស្ត្រ DTIS បានពិនិត្យមើលគោលនយោបាយទាក់ទិនពាណិជ្ជកម្មនានា និង បានកំណត់វិធានការទាំងឡាយដើម្បីជួយឱ្យប្រទេសកម្ពុជាបំពេញបាននូវករណីយកិច្ចអង្គការពាណិជ្ជកម្មពិភពលោក រួមមានកំណែទម្រង់ច្បាប់ និងការកែលម្អបទដ្ឋាននៃការនាំចេញចំណីអាហារកម្ពុជា។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលក៏កំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ផងដែរក្នុងការរៀបចំអភិក្រមទូទាំងវិស័យពាណិជ្ជកម្ម ដើម្បីគាំទ្រការអនុវត្តន៍អនុសាសន៍គោលនយោបាយស្របតាមយុទ្ធសាស្ត្រ DTIS។ មានឈ្មោះខ្លីហៅថា Trade SWAp ។ អភិក្រមនេះ នឹងអនុញ្ញាតឱ្យដៃគូអភិវឌ្ឍន៍នៅកម្ពុជាអាចតម្រង់មូលនិធិទៅលើសកម្មភាពផ្សេងៗជាច្រើន ដែលសកម្មភាពទាំងអស់នេះធ្វើការងារឆ្ពោះទៅកាន់គោលដៅទាំងឡាយដែលត្រូវបានកំណត់ដោយយុទ្ធសាស្ត្រ DTIS។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឯកឧត្តម គាត ឈន់** មានប្រសាសន៍ថា: អភិក្រមនេះគួបផ្សំជាមួយនឹងការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) មានលក្ខណៈជាកម្មវិធីសមស្របនឹងពេលវេលាមួយ ដែលគាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចកម្ពុជា។

**ឯកឧត្តម គាត ឈន់** មានប្រសាសន៍ថា *"គោលបំណងនៃគម្រោងនេះ គឺការកែលម្អផលប៉ះពាល់អភិវឌ្ឍន៍នៃឱវាទរបស់ស្ថាប័នផ្តល់ជំនួយ និង បង្កើនឱ្យបានច្រើននូវភាពជាម្ចាស់ផ្ទាល់របស់រាជរដ្ឋាភិបាលលើការបង្កើត និងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម"* ។

ភារៈធារីស្តីទីប្រតិភូគណៈកម្មការអឺរ៉ុបប្រចាំមកម្ពុជា លោក Rafael Dochao Moreno មានប្រសាសន៍ថា *"លើកពីតំបន់ផ្សេងៗទៀតនៅក្នុងពិភពលោក សហភាពអឺរ៉ុប បានដឹងយ៉ាងច្បាស់អំពីផលប្រយោជន៍នៃជំនួញចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។ សហភាពអឺរ៉ុប គឺជាអ្នកផ្តល់ជំនួយបច្ចេកទេសដែលទាក់ទិនទៅនឹងការអភិវឌ្ឍជំនួញធំជាងគេបំផុតនៅលើពិភពលោក ហើយក៏ជាទីផ្សារធំជាងគេបំផុតដែរសំរាប់ការនាំចេញពីប្រទេសផ្សេងៗ ហើយយើងក៏បានផ្តល់ការរួចពន្ធចំពោះទំនិញនាំចេញពីប្រទេសដែលមានការអភិវឌ្ឍនៅទន់ខ្សោយ ដូចជាប្រទេសកម្ពុជា ដែលនៅក្រោមកិច្ចព្រមព្រៀងដែលមានឈ្មោះថា EBA ចំពោះប្រព័ន្ធជំនួញ។ ការផ្តល់ថវិកាលើការងារនេះនៅកម្ពុជា គឺស្របទៅនឹងយុទ្ធសាស្ត្រគាំទ្ររបស់គណៈកម្មការអឺរ៉ុបសំរាប់ប្រទេសកម្ពុជា "*។